សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីថ្ងៃបុណ្យចូលឆ្នាំខ្មែរ
ដែលនៅថ្ងៃបុណ្យចូលឆ្នាំខ្មែរប្រជាជនខ្មែរតែងតែរៀបចំបាយសម្ល និងទិញសម្លៀកបំពាក់ថ្មីៗ
ដើម្បីជូនឪពុកម្តាយឬក៏អ្នកមានគុណ
និងពួកគាត់បានរៀបចំបាយសម្លបង្អែមផ្លែឈើជាមួយនឹងស្លាដក់មួយផ្នែកទៀត
ដើម្បីយកទៅប្រគេនព្រះសង្ឃនៅក្នុងវត្ត
ដើម្បីឧទ្ទិសទៅដល់សាច់ញាតិជីដូនជីតាដែលបានស្លាប់ទៅ។

ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១ យើងឃើញមានគ្រួសារមួយ
ដែលមានឪពុកម្តាយនិងកូនដើរនៅខាងក្រោយ។ ពួកគាត់ទាំងបីកំពុងតែ ពួកគាត់ទាំងបីកំពុងតែដើរ
កំពុងតែដើរឡើងទៅលើវិហារដើម្បីនាំយករបស់ទាំងអស់នោះយកទៅប្រគេនព្រះសង្ឃ។
ដោយរបស់ទាំងអស់នោះរួមមានដូចជាបាយ សម្ល និងស្លាដក់ផងដែរ
ដើម្បីយកទៅប្រគេនព្រះសង្ឃ។ ជាទូទៅប្រជាជនខ្មែរនៅថ្ងៃបុណ្យចូលឆ្នាំខ្មែរតែងតែទៅវត្ត
អ្នកខ្លះប្រសិនបើគាត់រវល់ គាត់ទៅវត្តតែមួយថ្ងៃនៅក្នុងរយៈពេលបីថ្ងៃនោះ
អ្នកខ្លះគឺគាត់ទៅទាំងបីថ្ងៃ គឺគាត់ទៅទាំងបីថ្ងៃ
ប៉ុន្តែនៅថ្ងៃបុណ្យចូលឆ្នាំខ្មែរគឺប្រជាជនខ្មែរទាំងអស់គឺឈប់សម្រាក ពួកគាត់អត់ធ្វើការទេ
ពួកគាត់អត់ធ្វើការទេ។ អញ្ចឹងជាទូទៅពួកគាត់ត្រូវទៅវត្ត
និងទៅលេងសាច់ញាតិរបស់គាត់នៅតាមខេត្ត ឬក៏ នៅតាមស្រុកស្រែជនបទ។
អញ្ចឹងពួកគាត់ទាំងបីអ្នកដែលមានឪពុក ម្តាយ និងកូន ពួកគាត់ទាំងបីនាក់កំពុងតែដើរឡើងវិហារ
ដើម្បីយក ដើម្បីយករបស់ទាំងអស់នោះទៅប្រគេនព្រះសង្ឃ។
ប៉ុន្តែនៅពេលដែលគាត់ឡើងទៅលើវិហារគាត់ត្រូវដោះស្បែកជើង
គាត់ត្រូវដោះស្បែកជើងជាមុនសិន ពីព្រោះនៅពេលដែលឡើងវិហារយើងអត់
យើងអត់អាចពាក់ស្បែកជើងបានទេ
ប្រសិនបើពាក់ស្បែកជើងមានន័យថាយើងអត់គោរពព្រះសង្ឃឬក៏ គោរព
យើងអត់គោរពព្រះសង្ឃឬក៏ ឬក៏ យើងអាចមានបាបផងដែរ ដោយសារតែការមិនគោរព។
អញ្ចឹងជាទូទៅនៅពេលដែលប្រជាជនខ្មែរចូលទៅក្នុងវត្តពួកគាត់ត្រូវដោះមួកចេញ
និងជាពិសេសនៅពេលដែលគាត់ឡើងទៅលើវិហារ ឡើងទៅលើវិហារ
ពួកគាត់ត្រូវដោះស្បែកជើងនិងដោះមួក ដើម្បីជាការគោរព។
អញ្ចឹងពួកគាត់ទាំងបីកំពុងតែដើរឡើងទៅលើវិហារដើម្បីយក ដើម្បីយកបាយសម្ល
និងស្លាដក់ទៅប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិស ដើម្បីឧទ្ទិសទៅដល់សាច់ញាតិរបស់គាត់
ទៅដល់សាច់ញាតិរបស់គាត់ ដែលមានជីដូនជីតា និងបងប្អូនដែលបានស្លាប់ទៅនោះ
ដើម្បីឲ្យពួកគាត់ទាំងអស់បានទទួលយករបស់ទាំងនោះ បានទទួលយករបស់ទាំងនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងនៅពេលដែលពួកគាត់ទទួលបានរបស់ទាំងអស់នោះហើយ។
ពួកយើងមានជំនឿថាពួកគាត់នឹងជួយថែរក្សាពួកយើងឲ្យជួបតែសេចក្ដីសុខ
និងអ្វីដែលយើងប៉ងប្រាថ្នាក៏អាចបានសម្រេចផងដែរ
ពីព្រោះដោយសារតែការធ្វើអំពីល្អការដឹងគុណរបស់យើង។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ យើងឃើញ
យើងឃើញពួកគាត់ទាំងបីនាក់បានដើរចូលទៅខាងក្នុងវិហារ
ដោយយើងឃើញពួកគាត់ទាំងបីនាក់គឺដោះស្បែកជើង គឺដោះស្បែកជើង អត់មានពាក់ស្បែកជើង
និងពាក់មួក ឬក៏បង់កន្សែងនៅលើក្បាលរបស់ពួកគាត់ទាំងអស់គ្នាទេ។
ដោយសារតែពួកគាត់ត្រូវយក ត្រូវយក
ត្រូវយកបាយសម្លនិងស្លាដក់មកប្រគេនព្រះសង្ឃនៅក្នុងវត្ត។
អញ្ចឹងយើងឃើញពួកគាត់ដោះស្បែកជើង ជាទូទៅប្រជាជនខ្មែរនៅពេលដែលពួកគាត់ទៅវត្ត
គឺពួកគាត់តែងតែស្លៀក ពួកគាត់តែងតែស្លៀកពាក់អាវសជាមួយនឹងហូលផាមួង
ឬក៏អាវប៉ាក់ជាមួយនឹងហូលផាមួង។ ប៉ុន្តែក្មេងៗវិញ
ប៉ុន្តែក្មេងៗវិញភាគច្រើនពួកគាត់ចូលចិត្តស្លៀកអាវសជាមួយនឹងខោខៀវ
ឬក៏អាវសជាមួយនឹងសំពត់ខៀវដែលជាឯកសណ្ឋានរបស់សិស្ស ដែល
ដែលជាឯកសណ្ឋានសិស្សសាលា។ អញ្ចឹងភាគច្រើនគាត់
គាត់ស្លៀកឯកសណ្ឋានសិស្សសាលាមកវត្ត និងមនុស្សចាស់ភាគច្រើនគាត់ពាក់ហូល
ឬក៏សំពត់ជាមួយនឹងអាវពណ៌ស ឬក៏ ឬក៏អាវប៉ាក់ ឬក៏អាវប៉ាក់បែបមនុស្សចាស់ ឬក៏អាវ ឬក៏អាវដៃ
ឬក៏អាវធម្មតាពណ៌សដៃខ្លី ឬក៏អាវធម្មតាដៃវែងស្លៀកជាមួយនឹងសំពត់ ឬក៏ហូល និង
អ្នកខ្លះទៀតគឺគាត់ចូលចិត្តស្លៀកអាវប៉ាក់ជាមួយនឹងហូលឬក៏ផាមួងដើម្បីមកវត្ត។
និងមនុស្សប្រុសវិញ គឺភាគច្រើនគឺគាត់ពាក់ គាត់ស្លៀកខោពណ៌ខ្មៅជាមួយនឹងអាវពណ៌ស
អញ្ចឹងគាត់ស្លៀកខោពណ៌ខ្មៅជាមួយនឹងអាវពណ៌សមកវត្ត។
អញ្ចឹងក្មេងៗពេលខ្លះគឺគាត់ចូលចិត្តស្លៀកពាក់ឯកសណ្ឋាន ស្លៀកពាក់ឯកសណ្ឋានសិស្សសាលា
ប៉ុន្តែខ្លះទៀតគឺគាត់ពាក់ជារបៀបខោ ខោធម្មតា និងអាវធម្មតាពណ៌ស
អញ្ចឹងក្មេងៗយើងអត់ប្រកាន់ខឹងពួកគាត់ទេ យើងអត់ប្រកាន់
អញ្ចឹងពួកគាត់អាចស្លៀកពាក់ខោអាវខុសពីអាវពណ៌សនិងសំពត់ខៀវ
ឬក៏អាវពណ៌សនិងខោពណ៌ខៀវបាន។ អញ្ចឹងជាក់ស្តែងយើងឃើញឪពុក យើងឃើញគាត់
យើងឃើញគាត់ពាក់អាវពណ៌ យើងឃើញគាត់ពាក់អាវពណ៌ ពណ៌ស
យើងឃើញគាត់ពាក់អាវពណ៌សដៃខ្លី ដៃខ្លី ជាមួយនឹងខោពណ៌សជើងវែង
ជាមួយនឹងខោពណ៌សជើងវែង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងម្តាយយើងឃើញពាក់អាវពណ៌សដៃខ្លីជាមួយនឹងសំពត់ហូលជើងវែង។
អញ្ចឹងយើងឃើញឪពុកដែលដើរនៅខាងមុខ យើងឃើញគាត់មានកាន់ស្លាដក់នៅក្នុងដៃរបស់គាត់។
ដែលស្លាដក់ទាំងអស់នោះ គឺ ដែលស្លាដក់ ដែលស្លាដក់នោះនៅក្នុងនោះ គឺយើងមានដាក់សៀវភៅ
សាប៊ូ ឬ សាប៊ូ ឬក៏ជា ជាភេសជ្ជៈផ្សេងៗ ឬក៏ជា ឬក៏ជា ជាស្ករ ជាតែ ឬក៏ជាកាហ្វេ
ជាទឹកដោះគោដែលដាក់ ដែលដាក់នៅក្នុងស្លាដក់តែមួយនោះ
អញ្ចឹងស្លាដក់មួយគឺមានរបស់ជាច្រើននៅក្នុងនោះ គឺមានរបស់ជាច្រើននៅក្នុងនោះ។
អញ្ចឹងជាក់ស្តែងយើងឃើញឪពុកគឺកាន់ស្លាដក់ធំមួយ កាន់ស្លាដក់ធំមួយនៅក្នុងដៃរបស់គាត់
ដែលនៅក្នុងស្លាដក់មានរបស់ជាច្រើន ដែលមានទឹកដោះគោ ស្ករស សៀវភៅ
និងរបស់ជាច្រើនទៀត។ និងយើងឃើញម្តាយគឺគាត់ដើរខាងក្រោយឪពុក គឺគាត់ដាក់ដៃទាំងពីរ
គឺគាត់ដាក់ដៃទាំងពីរទម្លាក់ចុះ [...] ដៃទាំងពីរគឺគាត់ទម្លាក់ចុះ និងកូនរបស់គាត់ដើរនៅខាងក្រោយ
ដោយកូនរបស់គាត់គឺស្លៀកខោជើងខ្លីពណ៌សជាមួយនឹងអាវដៃខ្លីពណ៌ពងមាន់
ជាមួយនឹងអាវដៃខ្លីពណ៌ពងមាន់ អញ្ចឹងពួកគាត់ទាំងបីនាក់គឺចូលទៅក្នុងវិហារនិងដោះស្បែកជើង
ដោះស្បែកជើង។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣
ក្រោយពេលដែលពួកគាត់ដើរចូលទៅក្នុងវិហារក៏បានឃើញ ក៏ពួក
នៅពេលដែលគាត់ដើរចូលទៅក្នុងវិហារ
ពួកគាត់ក៏បានយកស្លាដក់ដែលគាត់កាន់នៅក្នុងដៃរបស់គាត់ធំនោះ យកទៅប្រគេនព្រះសង្ឃ
ដែលគង់នៅ ដែលគង់នៅក្នុងវិហារនោះ។ អញ្ចឹងជាទូទៅភាសា យើងហៅថាអង្គុយ
ប៉ុន្តែភាសាព្រះសង្ឃយើងហៅថាគង់ អញ្ចឹងព្រះសង្ឃគង់នៅក្នុងព្រះវិហារ
មានន័យថាព្រះសង្ឃគាត់[អង្គុយ] ព្រះសង្ឃលោកអង្គុយនៅក្នុងព្រះវិហារ
អញ្ចឹងភាសារបស់ព្រះសង្ឃយើងហៅថាគង់ អញ្ចឹងយើងឃើញព្រះសង្ឃគង់នៅក្នុង
គង់នៅក្នុងព្រះវិហារ។ បន្ទាប់មកឪពុក ឪពុក ក៏បាន បន្ទាប់មកឪពុកក៏បានអង្គុយលុតជង្គង់
អង្គុយលុតជង្គង់ និងលើកដៃទាំងពីរសំពះ ដែលដាក់ស្លាដក់នៅខាងមុខគាត់ដើម្បីរៀបចំប្រគេន
ប្រគេនព្រះសង្ឃ។ អញ្ចឹងមុនពេលប្រគេនយើងត្រូវ យើងត្រូវលុតជង្គង់
ប្រសិនបើយើងត្រូវលុតជង្គង់ ឬក៏អង្គុយបត់ជើង លុតជង្គង់ ឬក៏អង្គុយបត់ជើង
ប្រសិនបើជាស្ត្រីគាត់ត្រូវអង្គុយបត់ជើង ឬក៏គាត់អាចលុតជង្គង់ផងដែរ។
ប៉ុន្តែជាទូទៅភាគច្រើនគឺយើងអង្គុយបត់ជើង គឺយើងអង្គុយបត់ជើង
និងសំពះចំនួនបីដងមុនពេលប្រគេន មុនពេលប្រគេនស្លាដក់នោះទៅកាន់ព្រះសង្ឃ
អញ្ចឹងយើងត្រូវសំពះដើម្បីគោរពព្រះសង្ឃជាមុនសិន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀត បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ យើងឃើញនៅក្នុងវត្តគឺមាន យើងឃើញវត្ត នៅក្នុងវត្តគឺយើងអុជធូប និងមានអុជធូប និងមានដាក់ផ្កាដែលជាទូទៅយើងប្រើផ្កាឈូក ឬក៏ផ្កាម្លិះ ផ្កាឈូក ឬក៏ ផ្កាម្លិះ និងមានទៀនផងដែរ។ ការអុជធូបគឺដើម្បី ដើម្បីហៅសាច់ញាតិរបស់យើង ដើម្បីប្រាប់គាត់ថាយើងបានយក បានយកបាយសម្លនិងម្ហូបអាហារ យកមក យកមកប្រគេនព្រះសង្ឃនិងឧទ្ទិសទៅឲ្យគាត់ និងឧទ្ទិសទៅឲ្យគាត់។ ការអុជទៀន ការអុជទៀនគឺយើងចង់ឲ្យ យើងចង់ឲ្យនៅ នៅ យើងចង់ឲ្យនៅជាតិក្រោយ មានន័យថានៅពេលដែលយើងស្លាប់ទៅជាតិក្រោយ យើងកើតមកគឺ យើងកើតមកគឺមាន គឺមានប្រាជ្ញា គឺមានប្រាជ្ញាឆ្លាតវៃ ដោយសារតែពន្លឺទៀនអាចនាំផ្លូវយើង អាចបំភ្លឺផ្លូវយើង អញ្ចឹងយើងអាចមានប្រាជ្ញាឆ្លាតវៃ យើងអាចមានប្រាជ្ញាឆ្លាតវៃ និងថ្វាយផ្កា មានន័យថានឹងយើងយកផ្កាទៅវត្ត ដើម្បីថ្វាយ[ព្រះ] ដើម្បីថ្វាយព្រះពុទ្ធ ដើម្បីយកទៅថ្វាយព្រះពុទ្ធ។ អញ្ចឹងមានន័យថាយើងចង់ឲ្យជាតិក្រោយ យើងស្អាតដូចជាផ្កា យើងស្អាតដូចជាផ្កា និងមាន និងស្អាតដូចជាផ្កានិងដូចជាផ្កាម្លិះ មានក្លិនក្រអូបដូចជាផ្កា និងទៅណាមកណាមានគេចូលចិត្ត មានគេគោរពស្រឡាញ់។ អញ្ចឹងជាទូទៅនៅក្នុងវត្តយើងយកធូប ទៀន និងផ្កា យកទៅប្រគេនព្រះសង្ឃ និងដាក់ផ្កាថ្វាយព្រះពុទ្ធ ដាក់ផ្កាថ្វាយព្រះពុទ្ធ។ និងបន្ទាប់មកទៀតយើងឃើញ យើងឃើញគាត់អុជធូបដាក់ដោតនៅក្នុង ដាក់ដោតនៅក្នុង ដាក់ដោតនៅក្នុងក្រឡដែលមានខ្សាច់។ អញ្ចឹងក្រឡទាំងអស់នោះគឺយើងដាក់ខ្សាច់ចូលទៅខាងក្នុងដើម្បីងាយស្រួលដោតធូប ដើម្បីងាយស្រួលដោតធូប និងនៅក្នុងវត្តយើងមានថូផ្កាដើម្បីប្រជាជន ដើម្បីពេលដែលប្រជាជនខ្មែរមកវត្តគាត់អាចដាក់ផ្កាចូលទៅក្នុងថូនោះដើម្បីថ្វាយទៅដល់ព្រះពុទ្ធ និងយើងអាចអុជទៀននៅខាងមុខរូបសំណាក់របស់ព្រះពុទ្ធផងដែរ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៥ រូបភាពទី ៥ ក្រោយពេលដែលពួកគាត់បានប្រគេន ប្រគេនស្លាដក់ បានប្រគេនស្លាដក់ទៅឲ្យព្រះសង្ឃរួចរាល់ហើយ និងបានអុជធូប និងបានអុជធូបនៅក្នុងព្រះវិហាររួចរាល់ហើយ។ ពួកគាត់ទាំងបីនាក់ក៏ដើរត្រលប់មកវិញ ក៏ដើរចុះមកវិហារវិញដើម្បី ក៏បានដើរចុះ កាំជណ្ដើរចុះពីវិហារវិញ ដើម្បីត្រលប់ទៅផ្ទះរបស់គាត់ ដើម្បីទៅសួរ ដើម្បីទៅលេងឪពុកម្ដាយរបស់គាត់ ដើម្បីទៅលេងឪពុកម្ដាយរបស់គាត់នៅ នៅតាមខេត្ត។ អញ្ចឹងយើងឃើញឪពុកគឺដើរនាំមុខ បន្ទាប់មកម្ដាយនិងកូនប្រុសគាត់គឺដើរនៅខាងក្រោយ។ អញ្ចឹងពួកគាត់ទាំងបីនាក់ ក្រោយពេលប្រគេនស្លាដក់ហើយពួកគាត់ក៏បាន ពួកគាត់ក៏បានចុះ ពួកគាត់ក៏បានចុះពីកាំជណ្ដើរ[ព្រះវិហារ] កាំជណ្ដើរវិហារដើម្បីត្រលប់ទៅផ្ទះវិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៦ រូបភាពទី ៦ ពួកគាត់ទាំង
ពួកគាត់ទាំងបីនាក់ក៏បានជិះម៉ូតូត្រលប់ទៅផ្ទះវិញ។ អញ្ចឹងយើងឃើញឪពុកជាអ្នកបើក
បន្ទាប់មកកូនជិះនៅកណ្តាលនិងម្តាយជិះនៅខាងក្រោយ។
យើងឃើញម្តាយដោយសារតែគាត់ស្លៀកសំពត់ ដូច្នេះគាត់ត្រូវជិះចំហៀង គាត់ត្រូវជិះចំហៀង
ពីព្រោះដោយសារតែគាត់ស្លៀកសំពត់ និងពេលខ្លះ
និងពេលខ្លះមនុស្សស្រីភាគច្រើនគាត់ជិះចំហៀង។ ប៉ុន្តែនៅពេលដែលគាត់ស្លៀកខោគឺ
ពេលខ្លះគឺគាត់ជិះចំហៀងដែរ។ ប៉ុន្តែពេលខ្លះគាត់ជិះច្រកកៀវ ច្រកកៀវ។ អញ្ចឹងនៅក្នុងរូបភាពនេះ
ដោយសារតែគាត់ស្លៀកសំពត់ដូច្នេះគាត់ត្រូវជិះចំហៀង ដែលកូនប្រុស
ដែលកូនប្រុសរបស់គាត់ជិះនៅកណ្តាល និងឪពុកជាអ្នកបើកម៉ូតូ។
អញ្ចឹងយើងឃើញម៉ូតូរបស់គាត់គឺមាន គឺមាន យើងឃើញមានកញ្ចក់ពីរដាក់អម ដាក់អមសងខាង
ដើម្បីងាយស្រួលមើលនៅខាងក្រោយ និងមានចង្កៀង ឬក៏អំពូល អំពូលភ្លើងម៉ូតូនៅខាងមុខ
ដែលមានអំពូលភ្លើងធំ ដែលប្រើសម្រាប់បំភ្លឺផ្លូវនៅពេលដែលមានភ្លៀង
ឬក៏នៅពេលដែលមេឃងងឹត ឬក៏នៅពេលដែលគាត់ពិបាកមើលផ្លូវ គាត់អាច
នៅពេលដែលមានភ្លៀង ឬក៏មេឃងងឹត គាត់ពិបាកមើលផ្លូវគាត់អាចបើកភ្លើងនោះដើម្បីបំភ្លឺផ្លូវ។
ប៉ុន្តែគាត់អត់បានពាក់មួកការពារសុវត្ថិភាពទេ ដោយសារតែ ដោយសារតែនៅក្នុង
ដោយសារតែវត្តនិងផ្ទះរបស់គាត់គឺនៅជិតគ្នា ដូច្នេះគាត់អត់ពាក់មួកសុវត្ថិភាពទេ។
បន្ទាប់មកទៀតគាត់ក៏បានជិះម៉ូតូដើម្បីទៅលេង ដើម្បីទៅលេងឪពុកម្តាយរបស់គាត់
ដើម្បីទៅលេងឪពុកម្តាយរបស់គាត់។

រូបភាពទី ៧ គាត់ក៏បានមកដល់ផ្ទះឪពុកម្តាយរបស់គាត់
ដែលយើងឃើញផ្ទះរបស់ឪពុកម្តាយរបស់គាត់ យើងឃើញមាន
យើងឃើញធ្វើអំពីឈើនិងប្រក់ដំបូលក្បឿង ប្រក់ដំបូលក្បឿង និងមានកាំជណ្តើរឡើងទៅខាងលើ។
ជាទូទៅ ជាទូទៅ យើងធ្វើផ្ទះភាគច្រើនយើង យើងធ្វើជាលក្ខណៈបែបខ្មែរដែលធ្វើអំពីឈើ
និងមានកាំជណ្តើរឡើងទៅខាងលើ ដោយសារតែពេលខ្លះនៅខាងក្រោមយើងអាចដាក់គ្រែ
ដើម្បីអង្គុយលេង ឬក៏មានពាងទឹក ឬក៏ពេលខ្លះចង្ក្រានបាយគឺយើងធ្វើនៅខាងក្រោមផ្ទះ
ប៉ុន្តែប្រហែលជានៅក្នុងរូបភាពនេះគឺ
នៅផ្ទះរបស់ឪពុកម្តាយគាត់គឺនៅពេលដែលមានភ្លៀងគឺមានទឹកលិច
ដូច្នេះគាត់ត្រូវធ្វើផ្ទះឲ្យរាងខ្ពស់បន្តិចដើម្បីការពារនៅពេលដែលមានភ្លៀងកុំឲ្យទឹកលិចផ្ទះរបស់គាត់
ដើម្បីកុំឲ្យទឹកលិចចូលផ្ទះរបស់គាត់ អញ្ចឹងគាត់ធ្វើផ្ទះរបស់គាត់ឲ្យរាងខ្ពស់បន្តិច ឲ្យរាងខ្ពស់បន្តិច។
អញ្ចឹងនៅពេលដែលមានភ្លៀងទឹកអត់លិចចូលផ្ទះរបស់គាត់
និងនៅពេលដែលអត់ភ្លៀងគាត់អាចអង្គុយលេងនៅក្រោមផ្ទះដែលមានខ្យល់ ដែលមានខ្យល់បក់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលមានខ្យល់ ដែលមានខ្យល់ ដែលមានខ្យល់បក់ត្រជាក់ស្រួល និងអាច
យើងអាចអង្គុយលេងនៅខាងក្រោមផ្ទះ ឬក៏យើងអាច
ជាទូទៅយើងធ្វើផ្ទះបាយនៅខាងក្រោមផ្ទះផងដែរ។ នៅខាងក្រោមផ្ទះផងដែរ។
អញ្ចឹងអាស្រ័យទៅលើពេលខ្លះគឺគាត់ធ្វើផ្ទះបាយនៅលើផ្ទះ ពេលខ្លះគាត់ធ្វើផ្ទះបាយនៅក្រោមផ្ទះ។
អញ្ចឹងពួកគាត់ទាំងបីនាក់បានមកដល់ផ្ទះឪពុកម្ដាយរបស់គាត់ដើម្បីមកសួរសុខទុក្ខពួកគាត់
ជាទូទៅប្រជាជនខ្មែរនៅពេលថ្ងៃបុណ្យចូលឆ្នាំខ្មែរ ពួកគាត់តែងតែ ពួកគាត់ក្រៅពីទៅវត្ត
ពួកគាត់តែងតែទៅលេងសាច់ញាតិឬក៏ឪពុកម្ដាយនៅតាមខេត្ត ឬក៏នៅតាមស្រុកស្រែចំការ
នៅតាមស្រុកស្រែចំការ ដើម្បីជួបជុំគ្នា ដើម្បីជួបជុំគ្នា ជជែកគ្នាលេង ឬក៏ញុាំអាហារជុំគ្នា
ដើម្បីញុាំអាហារជុំគ្នា។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ នៅពេលដែលគាត់
នៅពេលពួកគាត់ទាំងបីបានមកដល់ផ្ទះឪពុកម្ដាយរបស់គាត់
ពួកគាត់ទាំងបីក៏បានឈប់ម៉ូតូដាក់នៅខាង ដាក់នៅខាងក្រោមផ្ទះ ដាក់នៅខាងក្រោមផ្ទះ។
បន្ទាប់មកទៀតគាត់ក៏បានឡើងមកលើផ្ទះដើម្បីជួបឪពុកម្ដាយរបស់គាត់
នៅពេលដែលគាត់ឡើងមកដល់លើគាត់ក៏បានសួរសុខទុក្ខនិងជជែកគ្នាលេងជាមួយនឹង
និងជជែកគ្នាលេងជាមួយនឹងឪពុកម្ដាយរបស់គាត់។
បន្ទាប់មកគាត់ក៏ឲ្យឪពុកម្ដាយរបស់គាត់អង្គុយនៅលើកៅអី បន្ទាប់មកកូនប្រុសរបស់គាត់ក៏បាន
ក៏បានចុះទៅដួសទឹក ចុះទៅដួសទឹកមួយផ្ដិល និងឡើងមកលើផ្ទះវិញអង្គុយលុតជង្គង់
ដើម្បីយកទឹកនោះយកមកលាងដៃ ឬក៏លាងជើងឲ្យ ឲ្យជីដូនឬក៏ជីតា ឲ្យយាយឬក៏
ឲ្យយាយនិងតា។ នៅថ្ងៃបុណ្យចូលឆ្នាំខ្មែរភាគច្រើនគឺយើង
ក្រៅពីយើងទៅវត្តយើងមកសួរសុខទុក្ខឪពុកម្ដាយ។ យើងមកសួរសុខទុក្ខឪពុកម្ដាយ យើងជូនលុយ
ឬក៏យើងរៀបចំម្ហូប យើងជូនលុយឬក៏បាយសម្លជាមួយនឹងបាយសម្ល
និងពេលខ្លះគឺយើងទិញសម្លៀកបំពាក់ថ្មីៗដើម្បីជូនគាត់។ មិនត្រឹមតែប៉ុណ្ណោះយើង
ពេលខ្លះគឺយើងងូតទឹកឲ្យគាត់ដែលយើងហៅថាស្រង់ព្រះ ដែលយើងហៅថាស្រង់ព្រះ
ពីព្រោះដោយសារពួកគាត់ប្រៀបដូចជាព្រះរបស់យើង ដោយសារតែពួកគាត់គឺបានបង្កើតយើងមក
និងចិញ្ចឹមយើង[យ៉ាង] និងចិញ្ចឹមយើងយ៉ាងលំបាក ដូច្នេះយើង យើងមុជទឹកឲ្យគាត់ យើងមុជទឹក
ឬក៏សម្អាតដៃ សម្អាតជើងឲ្យគាត់ និងពាក់សម្លៀកបំពាក់ថ្មីឲ្យគាត់
និងស្លៀកពាក់សម្លៀកបំពាក់ថ្មីឲ្យគាត់។ ជាក់ស្ដែងយើងឃើញនៅក្នុងរូបភាពទី ៨
យើងឃើញកូនប្រុសរបស់គាត់បានដួសទឹកមួយផ្ដិលនិងលុតជង្គង់ដើម្បីលាង
លាងដៃនិងលាងជើងឲ្យ[ជី] លាងដៃ និងលាងជើងឲ្យយាយនិងឲ្យតា
ដែលពួកគាត់ទាំងពីរអង្គុយនៅលើកៅអី។ អញ្ចឹង គាត់បាន អញ្ចឹងឪពុកម្ដាយបានបង្រៀនកូនឲ្យ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឲ្យចេះគោរព ឲ្យចេះគោរពយាយតា ឲ្យចេះគោរពយាយតា និងលាងសម្អាតនិងលាងសម្អាតដៃជើង ឬក៏ពេលខ្លះយើងងូតទឹកឲ្យពួកគាត់ និងស្លៀកពាក់សម្លៀកបំពាក់ថ្មី។
អញ្ចឹងយើងឃើញឪពុកម្ដាយគឺឈរ គឺឈរ គឺឈរមើលកូន
គឺគាត់បានឲ្យកូនរបស់គាត់បានដួសទឹកមួយផ្ដិលដើម្បីលាងដៃលាងជើងយាយនិងតា ដើម្បី ដើម្បី ដើម្បី ដើម្បីជាការដឹងគុណ។

មកទៀតរូបភាពទី ៩ ពួកគាត់ក៏បានមករៀបចំ ពួកគាត់ក៏បានរៀបចំម្ហូបអាហារនិងញ៉ាំបាយជុំគ្នា។
យើងឃើញ យើងឃើញគ្រួសារគាត់ជាគ្រួសារតូចមួយដែលមានតែសមាជិកចំនួនប្រាំនាក់
យើងឃើញមានឪពុកម្ដាយ និងកូន និងមានជីដូនម្នាក់ជីតាម្នាក់
អញ្ចឹងពួកគាត់ទាំងប្រាំនាក់ក៏បានញ៉ាំបាយជុំគ្នា យើងឃើញពួកគាត់បានក្រាលកន្ទេលនៅលើ
បានក្រាលកន្ទេលនៅលើក្ដារនៅខាងលើផ្ទះ
បន្ទាប់មកទៀតយើងឃើញម្ហូបរបស់គាត់គឺមានដូចជាត្រី មានដូចជាត្រី និងសម្ល
និងមានបន្លែផ្សេងៗទៀត អញ្ចឹងពួកគាត់ទាំងអស់គ្នាញ៉ាំបាយជុំគ្នានៅថ្ងៃបុណ្យចូលឆ្នាំខ្មែរ។
អញ្ចឹងយើងឃើញ យើងឃើញបុរសគឺនៅពេលដែលគាត់អង្គុយញ៉ាំបាយគឺគាត់អង្គុយពែនភ្នែន
ពែនភ្នែន ប៉ុន្តែស្រី ស្ត្រី គឺនៅពេលដែលគាត់ញ៉ាំបាយគាត់អង្គុយបត់ជើង និងក្មេងៗដូចគ្នាដែរ
គាត់ត្រូវអង្គុយបត់ជើងដោយសារតែឪពុកម្ដាយនិងជីដូនជីតាគឺគាត់ចាស់ជាងយើង
ដូច្នេះយើងត្រូវអង្គុយបត់ជើងដើម្បីគោរពគាត់ ដើម្បីជាការគោរពគាត់។ កូនប្រុសដូចគ្នាដែរ។
ពេលខ្លះនៅពេលដែលយើងញ៉ាំបាយជាមួយនឹងឪពុកម្ដាយ
យើងត្រូវអង្គុយបត់ជើងដូចមនុស្សស្រីដែរដើម្បីជាការគោរពគាត់
ប៉ុន្តែប្រសិនបើយើងអង្គុយបត់ជើងចុកជើងទេ យើងអាចសុំអនុញ្ញាតពីគាត់អង្គុយពែនភ្នែន
យើងអាចសុំអនុញ្ញាតពីគាត់សិនមុនពេលដែលយើងអង្គុយពែនភ្នែន
អញ្ចឹងយើងឃើញពួកគាត់ទាំងប្រាំនាក់ញ៉ាំបាយជុំគ្នាជាមួយនឹងម្ហូបអាហារដែលមានក្លិនឈ្ងុយ
និងមានរសជាតិឆ្ងាញ់។ អញ្ចឹងមានក្លិនឈ្ងុយនិងមានរសជាតិឆ្ងាញ់។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ រូបភាពទី ១០ ក្រោយពេលដែលពួកគាត់ញ៉ាំ
ក្រោយពេលដែលពួកគាត់ញ៉ាំបាយជុំគ្នារួចរាល់ហើយ យើងឃើញក្មេងៗក៏បាននាំ ក៏បាន
ក្មេងៗក៏បាននាំគ្នាលេងនៅខាងក្រោយ នៅខាងក្រោមផ្ទះ នៅខាងក្រោមផ្ទះឬក៏នៅខាងក្រៅផ្ទះ
ដែលយើងឃើញក្មេងៗដែលជាបងប្អូនរបស់ ដែលយើងឃើញជាក្មេងៗដែលជាបងប្អូនរបស់គាត់
ដែលជាបងប្អូនរបស់ក្មេងប្រុសនោះ យើងឃើញពួកគាត់កំពុងតែលេងជះទឹកគ្នា និងលេងជះទឹកគ្នា
និងលេងបាញ់កាំភ្លើងទឹក [...] លេងបាញ់កាំភ្លើងទឹកទៅគ្នា ទៅគ្នាទៅវិញទៅមក។
អញ្ចឹងយើងឃើញ យើងឃើញក្មេងៗទៀត

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលយើងឃើញមានក្មេងៗផ្សេងទៀតដែលយើងឃើញមានក្មេងប្រុសម្នាក់និងក្មេងស្រីម្នាក់ទៀត។
អញ្ចឹងយើងឃើញក្មេងប្រុសនោះគាត់អត់ពាក់អាវទេ គាត់ស្លៀកតែខោខ្លីពណ៌ស
ដែលនៅក្នុងដៃរបស់គាត់មានកាន់កាំភ្លើងបាញ់ទឹក
និងក្មេងស្រីម្នាក់ទៀតគឺគាត់ពាក់អាវពណ៌ទឹកក្រូចដៃខ្លី ជាមួយនឹងខោពណ៌សជើងខ្លី ចងសក់ទីទុយ
នៅក្នុងដៃទាំងពីររបស់គាត់គឺមានកាន់ធុងទឹកមួយ
គាត់កំពុងតែជះទឹកដែលនៅក្នុងធុងនោះទៅក្មេងៗទាំងពីរនាក់នោះ ដែលក្មេង
ដែលក្មេងទាំងពីរនាក់នោះយើងឃើញគាត់មានកាំភ្លើងនៅក្នុងដៃ
យើងឃើញក្មេងប្រុសម្នាក់ទៀតគឺគាត់ពាក់អាវ
ក្មេងប្រុសម្នាក់ទៀតដែលគាត់មកជាមួយនឹងឪពុកម្តាយរបស់គាត់ ដើម្បីមកលេងជីដូន ជីដូនជីតា
និងបងប្អូនជីដូនមួយរបស់ បងប្អូនជីដូនមួយ ឬក៏សាច់ញាតិរបស់គាត់នោះ
យើងឃើញគាត់ពាក់អាវពណ៌ស យើងឃើញ[គាត់]
គាត់ពាក់អាវពណ៌ពងមាន់ដៃខ្លីជាមួយនឹងខោពណ៌សជើងខ្លី។
គាត់មានកាន់កាំភ្លើងបាញ់ទឹកនៅក្នុងដៃរបស់គាត់ផងដែរ។
និងនៅខាងក្រោយក្មេងស្រីយើងឃើញមានឆ្កែមួយក្បាល
ក៏កំពុងតែលេងជាមួយនឹងក្មេងៗទាំងអស់នោះផងដែរ។
អញ្ចឹងពួកគាត់ទាំងបីនាក់លេងជះទឹកគ្នាយ៉ាងសប្បាយរីករាយនៅក្នុងថ្ងៃបុណ្យចូលឆ្នាំខ្មែរ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ ក្រោយពេលដែលពួកគាត់
ក្រោយពេលដែលពួកគាត់លេងជះទឹកគ្នា និងបាញ់ បាញ់ទឹកដាក់គ្នា បាញ់ទឹកដាក់គ្នាចប់
គាត់ក៏បានយកម្សៅមកលាបមុខគ្នាទៅវិញទៅមក គាត់បានយកម្សៅលាបមុខគ្នាទៅវិញទៅមក
ដែលយើងឃើញនៅក្នុងដៃរបស់ក្មេងប្រុសមានម្សៅ
និងគាត់បានយកដៃប្រឡាក់ម្សៅនោះដើម្បីយកទៅលាបមុខក្មេងស្រី។
អញ្ចឹងគាត់បានប៉ាតម្សៅឬក៏លាបម្សៅដាក់គ្នាទៅវិញទៅមក ប៉ុន្តែម្សៅនោះគឺជាម្សៅក្រអូប
និងមិនប៉ះពាល់ទៅដល់មុខរបស់ពួកគាត់ [...] មិនប៉ះពាល់ទៅដល់មុខរបស់ពួកគាត់ទេ។
អញ្ចឹងពួកគាត់ យើងឃើញក្មេងប្រុស ដៃម្ខាងគឺកាន់ម្សៅ
ដៃម្ខាងទៀតគឺគាត់បានយកម្សៅទៅលាបនៅលើមុខរបស់ក្មេងស្រី។
អញ្ចឹងយើងឃើញមុខរបស់ពួកគាត់ទាំងពីរគឺមានម្សៅនៅលើមុខ និងខ្លួនរបស់គាត់គឺទទឹក
ដោយសារតែពួកគាត់លេងជះទឹកដាក់គ្នា
ឬក៏បាញ់ទឹកដាក់គ្នាទៅវិញទៅមកនៅថ្ងៃបុណ្យចូលឆ្នាំខ្មែរយ៉ាងសប្បាយរីករាយ។
បន្ទាប់មកទៀតយើងឃើញកំលោះក្រមុំមួយក្រុមដែលមានគ្នាប្រាំមួយនាក់ ប្រុសបីនាក់ ស្រីបីនាក់
យើងឃើញពួកគាត់[ទាំង] យើងឃើញ[ពួកគាត់]

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងឃើញពួកគាត់ទាំងអស់គ្នាស្លៀកពាក់លក្ខណៈជាបែបប្រពៃណី ជាបែបខ្មែរ ជាបែបប្រពៃណីខ្មែរ ដែលយើងឃើញប្រុសគឺយើងឃើញ គាត់ស្លៀកពាក់ គាត់ស្លៀកពាក់អាវពណ៌សដៃខ្លីជាមួយនឹងឡេវមួយជួរ និងមានឡេវមួយជួរនៅខាងមុខ និងជាមួយនឹងខោជើងវែងពណ៌ស និង និង បុរសម្នាក់ទៀតគឺគាត់ពាក់អាវ គាត់ពាក់អាវដៃខ្លី និងពាក់អាវដៃខ្លី និងមានឡេវមួយជួរនៅខាងមុខអាវរបស់គាត់ និងគាត់ពាក់ខោជើងវែងពណ៌ ពណ៌ខ្មៅ និងបុរសម្នាក់ទៀតយើងឃើញគាត់ពាក់អាវពណ៌សដៃខ្លីជាមួយនឹងខោជើងវែង ជាមួយនឹងខោជើងវែងពណ៌ស។ អញ្ចឹង [...] អញ្ចឹងយើងក្រឡេកមើលទៅខាងស្រីៗវិញ យើងឃើញពួកគាត់ស្លៀកពាក់បែបប្រពៃណីខ្មែរ ដែលមានជាអាវសជាមួយនឹងហូល ឬក៏ជាមួយនឹងផាមួង ឬក៏ជាមួយនឹងសំពត់ជើងវែង សំពត់ជើងវែង ដែលយើងហៅថាសំពត់បត់ យើងហៅថាសំពត់បត់។ អញ្ចឹងគាត់ស្លៀកសំពត់បត់ជាមួយនឹងអាវដៃខ្លីពណ៌ស ឬក៏ជាមួយនឹងអាវប៉ាក់។ អញ្ចឹងពួកគាត់[ទាំង] ពួកគាត់ ពួកគាត់ទាំងអស់គ្នាកំពុងតែលេងចោលឈូង។ ការលេងល្បែងចោលឈូងមានន័យថាគឺយើងយកក្រមា រុំវាមូលដូចជាបាល់ ពួកយើងច្រៀងចម្រៀង ពួកយើងច្រៀងចម្រៀងចោលឈូង បន្ទាប់មកយើងគប់ទៅឲ្យគ្នា នៅពេលដែល នៅពេលដែលខាងស្រីច្រៀងចម្រៀងចោលឈូងចប់ ខាងស្រីនឹងគប់ឈូងនោះទៅឲ្យខាងប្រុស នៅពេលខាងប្រុសចាប់ឈូងនោះបាន ខាងប្រុសនឹងគប់ឈូងនោះទៅកាន់ខាងស្រីវិញ នៅពេលដែលប៉ះចំ ប៉ះចំស្រីណាមួយ ពួកគាត់ទាំងអស់គ្នាត្រូវរាំ ពួកគាត់ទាំង ពួកគាត់ទាំងអស់គ្នាត្រូវរាំ ដើម្បីនាំយកឈូងនោះ ឈូងនោះ ទៅឲ្យបុរសវិញ។ អញ្ចឹងការលេងល្បែងចោលឈូងគឺសប្បាយដោយសារតែយើងមានច្រៀងនូវចម្រៀង និងមានគប់ឈូង និងមានការចោលឈូងគប់គ្នាទៅវិញទៅមក។ ប៉ុន្តែមិនមានន័យថាគប់គ្នាជាលក្ខណៈខ្លាំងៗទេ គឺយើងគ្រាន់តែជា គឺយើងគ្រាន់តែគប់គ្នាបែបលក្ខណៈលេង ដើម្បី ដើម្បីនៅពេលដែលអ្នកណាចាញ់គាត់អាចរាំ ដើម្បីយកឈូងនោះយកទៅប្រគល់ឲ្យអ្នកដែលឈ្នះ យកប្រគល់ឲ្យអ្នកដែលឈ្នះ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ១៣ រូបភាពទី ១៣ យើងឃើញក្រោយពេលដែលពួកគាត់លេង ក្រោយពេលដែលពួកគាត់លេងល្បែងចោលឈូងចប់ ពួកគាត់ក៏ប្តូរមកលេងល្បែងមួយទៀត។ [ទី ១៣] អញ្ចឹងពួកគាត់ ពួកគាត់មិនទាន់បានប្តូរមកលេងល្បែងផ្សេងទៀតទេ គាត់នៅលេងល្បែងចោលឈូងដដែល ប៉ុន្តែដោយសារតែខាងស្រីចាញ់ ដូច្នេះខាងប្រុសគឺគាត់បានច្រៀងចម្រៀង គឺគាត់បានច្រៀងចម្រៀង និងខាងស្រីគឺត្រូវរាំ គឺត្រូវរាំ អញ្ចឹងពេលខ្លះគឺគាត់ នៅពេលដែលខាងស្រីរាំពេលខ្លះខាងប្រុសគឺគាត់រាំជាមួយនឹងខាងស្រីដែរ។ ប៉ុន្តែពេលខ្លះគឺខាងស្រីត្រូវរាំដើម្បីយកឈូងនោះយកទៅឲ្យខាងប្រុស ដើម្បី ដើម្បី ជាការ ដើម្បី

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីជាការបញ្ជាក់ថាពួកគាត់គឺជាអ្នកចាញ់ អញ្ចឹងអ្នកឈ្នះគឺច្រៀងចម្រៀងអ្នកចាញ់គឺគាត់ត្រូវរាំ គឺគាត់ត្រូវរាំ អញ្ចឹងគាត់ រូបភាពទី ១៣ នេះគឺគាត់ត្រូវ គឺគាត់លេង គឺគាត់លេងចោលឈូងដដែល ប៉ុន្តែដោយសារតែខាងស្រីចាញ់ ដូច្នេះខាងស្រីត្រូវរាំ ខាងប្រុសគឺគាត់ត្រូវច្រៀងចម្រៀង។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ គាត់ក៏បានប្តូរ គាត់ក៏បានប្តូរលេងល្បែងផ្សេងមួយទៀត គាត់ក៏បានប្តូរលេងល្បែងផ្សេងមួយទៀត ដែលយើងហៅថា ដែលយើងហៅថាចាប់កូនខ្លែង ការលេងល្បែងចាប់កូនខ្លែង គឺយើងលេងដោយ យើងមាន យើងឃើញ យើងមានមេម្នាក់ គឺគាត់ត្រូវឈរនៅខាងមុខ កូនៗត្រូវតោងចង្កេះគ្នាទៅវិញទៅមក និងមានម្នាក់ទៀតគាត់គឺដើរតួជា គាត់ដើរតួជាអ្នកដែល គាត់ដើរតួជា គាត់ដើរតួជាអ្នកចាប់កូនមាន់ មានន័យថាអ្នកដែលនៅឈរខាងក្រោយគេនៅក្នុងជួរនោះ គាត់ត្រូវចាប់អ្នកដែលនៅឈរខាងក្រោយនោះ។ អញ្ចឹងអ្នកដែលនៅឈរខាងមុខដែលជាអ្នកការពារ គាត់ត្រូវការពារកូនរបស់គាត់ដែលនៅខាងក្រោយនោះ អញ្ចឹងគាត់ត្រូវចាប់ម្តងមួយៗ នៅពេលដែលគាត់ចាប់[បាន] នៅពេលដែលគាត់ចាប់បានកូនមាន់អស់ហើយគឺគាត់គឺជាអ្នកឈ្នះ គឺគាត់គឺជាអ្នកឈ្នះ។ ប៉ុន្តែនៅពេលដែលគាត់ចាប់អត់បានទេគឺគាត់គឺជាអ្នកចាញ់ បុរសម្នាក់ទៀតគឺជាអ្នកចាញ់។ អញ្ចឹងមានន័យថា មានន័យថាមានគ្នាពីរនាក់ មួយគឺជាអ្នក អ្នក មួយគឺជាអ្នកនាំមុខដោយការពារកូនៗដែលនៅឈរខាងក្រោយ និងម្នាក់ទៀតគឺជាអ្នកដែលតាមចាប់កូនមាន់ ដែលកូនមាន់នោះគឺតំណាងឲ្យអ្នកដែលនៅឈរខាងក្រោយ អ្នកដែលនៅឈរខាងក្រោយគឺតំណាងឲ្យកូនមាន់ អ្នកដែលឈរខាងក្រោយគឺតំណាងឲ្យកូនមាន់។ អញ្ចឹងគាត់ត្រូវចាប់ គាត់ត្រូវចាប់កូនដែលនៅខាងក្រោយនោះឲ្យអស់។ អញ្ចឹងការលេងល្បែងប្រជាប្រិយគឺមានច្រើន ក្រៅពីការលេងបោះឈូង និងការលេងល្បែងចាប់កូនមាន់ យើងមានល្បែងជាច្រើនទៀតដូចជាការលេងបោះអង្គុញ ការលេងបោះអង្គុញដូចជាយើងដាក់អង្គុញដាំនៅលើ ដាំនៅលើដី បន្ទាប់មកទៀត នៅពេលដែលយើងចែកចេញជាពីរ ចែកចេញជាពីរក្រុម ក្រុមទី ១ នៅពេលដែលគាត់បោះអង្គុញនោះទៅប៉ះ ទៅប៉ះ និងអង្គុញមួយទៀតឲ្យដួល អញ្ចឹងគាត់គឺ[...]អ្នកឈ្នះ គាត់អាចយកអង្គុញនោះទៅជួស ទៅជួសនឹងជង្គង់របស់អ្នកដែលចាញ់។ អញ្ចឹងល្បែងប្រជាប្រិយមានច្រើន និងការលេងល្បែងប្រជាប្រិយគឺ ការលេងល្បែងប្រជាប្រិយគឺសប្បាយរីករាយ គឺសប្បាយរីករាយ និងធ្វើឲ្យថ្ងៃបុណ្យចូលឆ្នាំខ្មែរនោះកាន់តែ កាន់តែសប្បាយរីករាយយ៉ាងខ្លាំង។ អញ្ចឹងពួកគាត់លេងល្បែងប្រជាប្រិយ លេងល្បែងប្រជាប្រិយដោយមិនប្រកាន់ថា ដោយមិនប្រកាន់គ្នាទៅវិញទៅមក។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.